**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**សាលាខេត្តកណ្ដាល**
លេខ :....០៩៧.......សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការបណ្ដោះអាសន្ន រៀបចំ និងគ្រប់គ្រងរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ ខេត្តកណ្ដាល

# អភិបាលខេត្តកណ្ដាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ.
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៤៦ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តកណ្ដាល.
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៨០ចុះថ្ងៃទី២៥ខែឧសភា ឆ្នាំ២០០១ស្ដីពីការបង្កើតរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ.
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាល ស្ដីពីការរៀបចំនិងគ្រប់គ្រងរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ.
- បានឃើញប្រកាសលេខ ៤២៧៤ប្រក. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.
- បានឃើញសេចក្ដីសម្រេចលេខ ១០៩ សសរ. ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ របស់សាលាខេត្តកណ្ដាល ស្ដីពីការកែសំរួលសមាសភាពគណៈកម្មការខេត្ត រៀបចំ និង គ្រប់គ្រងរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ.
- យោងលិខិតលេខ ២១៨ ធត. ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្ដីពីករណីស្នើសុំកំណត់ បែងចែកភារកិច្ច ទទួលខុសត្រូវ គ្រប់គ្រងរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ.
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្ត.

# សម្រេច

**ប្រការ១ ៖**

ត្រូវបានបង្កើតគណៈកម្មការបណ្ដោះអាសន្ន រៀបចំ និងគ្រប់គ្រងរមណីយដ្ឋានភ្នំព្រះរាជទ្រព្យស្រុកពញាឮ ខេត្តកណ្ដាល ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- លោកជំទាវ | សួស សារ៉ាម | អភិបាលរងខេត្ត | ប្រធាន |
| ២- លោក | គុង ស៊ីវមី | អភិបាលស្រុកពញាឮ | អនុប្រធាន |
| ៣- លោក | សុខ អឿន | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| ៤- លោក | សំ សុភី | ប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ៥- លោក | អ៊ិន យ៉ុម | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |

៦- លោក វុង គិរម្យ ប្រធានមន្ទីរធម្មការ និងសាសនាខេត្ត សមាជិក

៧- លោក អ៊ួម ផាត់ ប្រធានមន្ទីរបរិស្ថានខេត្ត សមាជិក

៨- លោក លី សុខធី ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត សមាជិក

៩- លោក ញ៉ែម តាកវិទ្ធី នាយផ្នែករដ្ឋបាលព្រៃឈើកណ្ដាល សមាជិក

១០- លោកឧត្តមសេនីយ៍ត្រី អ៊ាវ ចំរើន ស្នងការនគរបាលខេត្ត សមាជិក

១១- លោកឧត្តមសេនីយ៍ត្រី មាស សុវណ្ណ មេបញ្ជាការកងរាជអាវុធហត្ថខេត្ត សមាជិក

១២- លោកឧត្តមសេនីយ៍ត្រី ឈៀ ស៊ីផារ៉ា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកណ្ដាល សមាជិក

**ប្រការ២ ៖**

គណៈកម្មការនេះ មានភារកិច្ច ៖

-ចាត់វិធានការខ្ទេរដើម្បីការពារអភិរក្សនិងលើកតម្លៃរមណីយដ្ឋានភ្នំព្រះរាជទ្រព្យដែលមានទំហំផ្ទៃដី ៥០៨ ហិកតា ស្ថិតនៅឃុំផ្សារដែក និងឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្ដាល.

-គ្រប់គ្រងនិងត្រួតពិនិត្យការអនុវត្តរបស់មន្ទីរ អង្គភាពអាជ្ញាធរពាក់ព័ន្ធ ដែលមានភារកិច្ចទទួលខុសត្រូវក្នុងតំបន់រមណីយដ្ឋាន

-ធានាសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ និងរបៀបរៀបរយក្នុងតំបន់រមណីយដ្ឋាន.

-គ្រប់គ្រងនិងត្រួតពិនិត្យការធ្វើអាជីវកម្មបម្រើឲ្យផ្នែកទេសចរណ៍ សំដៅធានាគុណភាពសេវាកម្មនិងលើកតម្លៃរមណីយដ្ឋាន

-គ្រប់គ្រងនិងត្រួតពិនិត្យប្រាក់ចំណូលដែលបានមកពីប្រភពផ្សេងៗគ្រប់ប្រភេទនិងបែងចែកប្រកបដោយសមធម៌.

-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ និង ស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់ជួយដល់ការអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋាន.

-បូកសរុបសកម្មភាព រាយការណ៍ជូនអភិបាលខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធ ឲ្យបានទៀងទាត់រៀងរាល់ខែ.

-សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំសាមញ្ញ រៀងរាល់បីខែម្ដង និងប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ ប្រធានគណៈ-កម្មការ។

**ប្រការ៣ ៖**

ត្រូវបានប្រគល់ភារកិច្ចទទួលខុសត្រូវជូនបណ្ដាមន្ទីរ អង្គភាព អាជ្ញាធរពាក់ព័ន្ធ ជាជំនួយការគណៈកម្មការបណ្ដោះអាសន្នដូចខាងក្រោម៖

**ក-មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្ត ដឹកនាំដោយលោកប្រធានមន្ទីរ ទទួលខុសត្រូវ៖**

-ទទួលបន្ទុកការពារ អភិរក្ស ជួសជុល និងថែទាំបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រក្នុងតំបន់ស្នូល

-ធ្វើបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ និងសំណង់ប្រវត្តិសាស្ត្រក្នុងតំបន់រមណីយដ្ឋាន

-គ្រប់គ្រងបុគ្គលិកឆ្មាំ និងកម្មករទទួលបន្ទុកបោសសម្អាត និងថែទាំក្នុងបរិវេណតំបន់ស្នូល

-ត្រួតពិនិត្យរាល់សកម្មភាពសណ្ដាប់ធ្នាប់ របៀបរៀបរយនានា ដូចជា : ការជីកកកាយ រុះរើ និងការកសាងសំណង់ថ្មី ដែលត្រូវហាមឃាត់ និងសកម្មភាពអាជីវកម្មលក់ដូរ ថតរូប ដែលអាចឲ្យប៉ះពាល់ដល់តំបន់ស្នូល និង រំខានដល់ភ្ញៀវទេសចរណ៍.

-សហការជាមួយអាជ្ញាធរមូលដ្ឋាន គណៈបញ្ជាការឯកភាពគ្រប់ថ្នាក់ ក្នុងការការពារ សម្បត្តិបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ.

-ពិនិត្យផ្ដល់យោបល់ផ្នែកបុរាណវិទ្យា រាល់ការសាងសង់ ឬគម្រោងអភិវឌ្ឍនៅក្នុងរមណីយដ្ឋាន.

-ធ្វើរបាយការណ៍ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អភិបាលខេត្ត និងគណៈកម្មការ.

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អភិបាលខេត្តនិងគណៈកម្មការប្រគល់ជូន.

**ខ-មន្ទីរទេសចរណ៍ខេត្ត ដឹកនាំដោយលោកប្រធានមន្ទីរ ទទួលខុសត្រូវ៖**

-ការរៀបចំអភិវឌ្ឍផ្នែកសេវាកម្មទេសចរណ៍ និងផ្ដល់ព័ត៌មានស្ដីពីរមណីយដ្ឋានជូនភ្ញៀវទស្សនា.

-យកចិត្តទុកដាក់ស្វែងរកចំណូលបានមកពីវិស័យទេសចរណ៍ក្នុងរមណីយដ្ឋាន ដើម្បីជាគុណប្រយោជន៍ សម្រាប់ការថែរក្សា ការពារ និងចាត់ចែងគ្រប់គ្រងរមណីយដ្ឋាន.

-សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីបណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ទេសចរណ៍.

-រៀបចំឲ្យមានការត្រួតពិនិត្យជាប្រចាំលើគុណភាពសេវាទេសចរណ៍ នៅក្នុងរមណីយដ្ឋានដោយគោរពបទដ្ឋាននិងស្តង់ដារជាតិ-អន្តរជាតិ

-រាល់ការធ្វើអាជីវកម្មខាងផ្នែកទេសចរណ៍ មិនត្រូវធ្វើឲ្យប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណីវប្បធម៌ជាតិ សង្គម បរិស្ថាន និងត្រូវធានាឲ្យមានអនាម័យ និងសុខុមាលភាពដល់ភ្ញៀវទេសចរណ៍ ដែលមកកំសាន្ត.

-ត្រួតពិនិត្យនិងគ្រប់គ្រងរាល់ការលក់ដូរ ការថតរូប ឬសកម្មភាពនានា ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់ដល់រមណីយដ្ឋាន ឬរំខានដល់ការទស្សនារបស់ភ្ញៀវទេសចរណ៍.

-កំណត់ទីតាំង និងរៀបចំឲ្យមានបង្គន់អនាម័យ ធុងដាក់សំរាមឲ្យបានត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស.

-ការចេញ-ចូលរបស់ភ្ញៀវទេសចរណ៍ ត្រូវអនុវត្តតាមគោលការណ៍ច្បាស់លាស់ ដោយកម្រិតពេលវេលាចេញ-ចូល.

-ត្រួតពិនិត្យការចេញ-ចូលរថយន្តក្នុងតំបន់រមណីយដ្ឋាន រៀបចំឲ្យមានស្លាកសញ្ញាចរាចរកម្រិតល្បឿនបើកបរនិង តម្រូវឲ្យចូលចតនៅទីលានចំណតដែលបានកំណត់.

-ធ្វើរបាយការណ៍ជូនក្រសួងទេសចរណ៍ អភិបាលខេត្ត និងគណៈកម្មការ.

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងទេសចរណ៍ អភិបាលខេត្ត និងគណៈកម្មការប្រគល់ជូន.

**គ-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ដឹកនាំដោយលោកប្រធានមន្ទីរ ទទួលខុសត្រូវ៖**

-គ្រប់គ្រងប្រភពចំណូលដែលបានមកពី : សំបុត្រចូលទស្សនាកំសាន្ត, កម្រៃពីអាជីវកម្មថតរូប ឬថតវីឌេអូ អាជីវកម្មលក់ដូរគ្រប់ប្រភេទ ,កម្មវិធីសម្តែងសិល្បៈឬពិធីកំសាន្តផ្សេងៗទៀត និងការជួល ឬអនុញ្ញាតឲ្យប្រើប្រាស់ដីធ្លី ដែលគ្រប់គ្រងដោយអាជ្ញាធរដែនដី.

-ប្រាក់ចំណូលដែលប្រមូលបាន ត្រូវយកមកប្រើប្រាស់ដើម្បីជាគុណប្រយោជន៍សម្រាប់ការពារ ថែរក្សា ជាត់ចែងនិងគ្រប់គ្រងរមណីយដ្ឋាន.

-ទទួលខុសត្រូវក្នុងការអនុវត្តចំណូល-ចំណាយ និងគ្រប់គ្រង ត្រួតពិនិត្យប្រាក់ចំណូលគ្រប់ ប្រភេទ.

-ចំណែកនៃប្រាក់ចំណូលនេះ ត្រូវផ្តល់ជូនមន្ទីរ អង្គភាព អាជ្ញាធរដែលបំពេញភារកិច្ចផ្ទាល់ សម្រាប់ឧបត្ថម្ភលើកទឹកចិត្តដល់មន្ត្រីអនុវត្តការងារ និងប្រើប្រាស់សម្រាប់ការងារប្រចាំថ្ងៃ ដោយឈរលើគោលការណ៍ សមធម៌ និងផ្អែកតាមគុណសម្បត្តិនៃការងារ.

-ដើម្បីអនុវត្តចំណូល-ចំណាយឲ្យមានប្រសិទ្ធភាពត្រូវតែងតាំងមន្ត្រីមួយរូបជាជំនួយការដែលមានភារកិច្ចប្រមូលចំណូលកត់ត្រាតាមដាន និងធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូល-ចំណាយ.

-ប្រាក់ចំណូលដែលប្រមូលបានត្រូវបែងចែក ដូចខាងក្រោម៖

១-តម្កល់ទុកសម្រាប់គុណប្រយោជន៍ក្នុងការអភិរក្សរមណីយដ្ឋាន.............៣០%

២-សម្រាប់ការលើកទឹកចិត្តមន្ត្រីបម្រើការងារតាមជំនាញនិមួយៗ...............៧០%

-ធ្វើរបាយការណ៍ជូនអភិបាលខេត្ត និងគណៈកម្មការ.

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអភិបាលខេត្ត និងគណៈកម្មការប្រគល់ជូន ។

**ឃ-អាជ្ញាធរដែនដី ស្រុកពញាឭ និង គណៈបញ្ជាការឯកភាពខេត្ត ទទួលខុសត្រូវ៖**

-ធានានូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់និងរបៀបរៀបរយក្នុងរមណីយដ្ឋាន ជូនដល់ភ្ញៀវ ទេសចរណ៍ដែលមកទស្សនាកំសាន្ត.

-ទប់ស្កាត់រាល់សកម្មភាពបង្កការប៉ះពាល់គុណភាពបរិស្ថាន បណ្តាលមកពីភ្ញៀវទេសចរណ៍និងសាធារណជន.

-សហការទប់ស្កាត់ការបំផ្លាញព្រៃឈើ ការទន្ទ្រានយកដី សំណង់ខុសច្បាប់នៅក្នុងរមណីយដ្ឋាន.

-កសាងផែនការ ការពារ និងសហការជាមួយកម្លាំងនគរបាលការពារបេតិកភណ្ឌ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើស នៃការបំផ្លិចបំផ្លាញ ការលួច ការទិញ ឬលក់ ការដឹកជញ្ជូនបេតិកភណ្ឌសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ.

-សហការជាមួយកម្លាំងនគរបាលទេសចរណ៍ លើរាល់បញ្ហាពាក់ព័ន្ធនឹងសន្តិសុខ សុវត្ថិភាព ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិនៅក្នុងរមណីយដ្ឋាន.

-គ្រប់គ្រង ត្រួតពិនិត្យការចេញ-ចូលរបស់ភ្ញៀវទេសចរណ៍ តាមគោលការណ៍ច្បាស់លាស់ ដោយកម្រិតពេលវេលាចេញ-ចូល ក្នុងតំបន់ស្នូល.

-ត្រួតពិនិត្យការចេញ-ចូលរថយន្តក្នុងតំបន់ កម្រិតល្បឿនបើកបរ និងតម្រូវឲ្យចូលចតនៅទីលានចំណតដែលបានកំណត់.

-រាល់ការធ្វើអាជីវកម្ម មិនត្រូវធ្វើឲ្យប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ជាតិ សង្គម បរិស្ថាន និងត្រូវធានាឲ្យមានអនាម័យ និងសុខុមាលភាពដល់ភ្ញៀវទេសចរណ៍ ដែលមកកំសាន្ត.

-ត្រួតពិនិត្យ និងគ្រប់គ្រងរាល់ការ លក់ដូរ ការថតរូប ឬសកម្មភាពនានា ដែលអាចបណ្ដាលឲ្យមានផលប៉ះពាល់ដល់រមណីយដ្ឋាន ឬរំខានដល់ការទស្សនារបស់ភ្ញៀវទេសចរណ៍.

-កំណត់ទីតាំង និងរៀបចំឲ្យមានបង្គន់អនាម័យ ធុងដាក់សំរាមឲ្យបានត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស.

-ពិនិត្យសំណើសុំសាងសង់នៅក្នុងតំបន់ទ្រនាប់ ដោយគោរពទៅតាមបទប្បញ្ញត្តិជាធរមាន ព្រមទាំងតាមដានការសាងសង់ទៅតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ.

-ធ្វើរបាយការណ៍ជូនអភិបាលខេត្ត និងគណៈកម្មការ.

-អនុវត្តតាមបទបញ្ជា និងភារកិច្ចផ្សេងៗទៀត ដែលអភិបាលខេត្ត និងគណៈកម្មការប្រគល់ជូន។

ង-មន្ទីរធម្មការនិងសាសនា, មន្ទីរបរិស្ថាន, មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងនាយផ្នែករដ្ឋបាលព្រៃឈើកណ្ដាល ទទួលខុសត្រូវ ៖

-អនុវត្តភារកិច្ចជំនាញរៀងៗខ្លួន ផ្សារភ្ជាប់ទៅនឹងភារកិច្ចជាក់ស្តែងក្នុងតំបន់ទាំងបី សំដៅអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ.

-ធ្វើរបាយការណ៍ និង សុំអនុសាសន៍ពីថ្នាក់ដឹកនាំក្រសួង អភិបាលខេត្ត និងគណៈកម្មការ.

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអភិបាលខេត្ត និងគណៈកម្មការប្រគល់ជូន។

**ប្រការ៤ ៖**

ប្រធានមន្ទីរ អង្គភាព អាជ្ញាធរពាក់ព័ន្ធ មានភារកិច្ចចាត់តាំងមន្ត្រីរាជការក្រោមឱវាទ ឲ្យទទួលខុសត្រូវតាមភារកិច្ចជំនាញជាក់ស្តែង និង តាមការចាំបាច់ ។

**ប្រការ៥ ៖**

សេចក្តីសម្រេចលេខ១០៩ សសរ. ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦ ៖**

នាយករដ្ឋបាលខេត្ត អភិបាលស្រុកពញាឮ មន្ទីរ អង្គភាពពាក់ព័ន្ធ គណៈបញ្ជាការឯកភាពខេត្ត និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១និងប្រការ៣ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

កណ្តាល ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០១៤

**អភិបាលខេត្តកណ្តាល**

**ផៃ ប៊ុនឈឿន**

***កន្លែងទទួល*** :

-ក្រសួងមហាផ្ទៃ

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-ក្រសួងទេសចរណ៍

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងធម្មការ និងសាសនា

-ក្រសួងបរិស្ថាន

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-អគ្គនាយកដ្ឋានរដ្ឋបាលព្រៃឈើ

-អគ្គស្នងការដ្ឋាននគរបាលជាតិ

-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ

"<u>ដើម្បីគោរពជូនជ្រាប</u>"

-ដូចក្នុងប្រការ៦ "<u>ដើម្បីអនុវត្ត</u>"

-ឯកសារ-កាលប្បវត្តិ